ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៤០. ៤១ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីទៀងរាល់សប្ដាហ៍

ក

មាតិកា

I - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

១០-១១-១៩៩៥	អនុក្រឹត្យលេខ ១១៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការនគរបាលជាតិ	២០៧៤

២ - សេចក្តីសំរេច

០៣-១១-១៩៩៥	សេចក្តីសំរេចលេខ ៧៧ សសរ ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន	២០៧៥

II - ការងារបណ្តាក្រសួង

១ - ទីស្តីការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

១៤-១១-១៩៩៥	ប្រកាសលេខ ៣៦៣ សហវ.លសប្រក ស្តីពីការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់	២០៧៦

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

១៤-១១-១៩៩៥	ប្រកាសលេខ ៤៤៧ ពណ.បល.ប្រក ស្តីពីការប្រគល់ភារកិច្ចបន្ថែមជូនឯកឧត្តម គុប សំ	២០៧៨

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២

ប្រកាស

០២-១១-១៩៩៥	ប្រកាសលេខ ៧៩៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី សាង វត្ថា ជនជាតិខ្មែរ បន្តដំណើរការសិប្បកម្មកាត់ដេរ សំលៀកបំពាក់ និងស្បែកជើងគ្រប់ប្រភេទ	២០៨(
០៣-១១-១៩៩៥	ប្រកាសលេខ ៨០១ ករ.ប្រក អនុញ្ញាតអោយក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT CO., LTD ធ្វើប្រតិបត្តិការសិក្សាស្រាវជ្រាវស្វែងរករកធនធានរ៉ែ នៅតំបន់ បរខាំ បរកែវ ខេត្តរតនគិរី	២០៨០
០៣-១១-១៩៩៥	ប្រកាសលេខ ៨០២ ករ.ប្រក អនុញ្ញាតអោយក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT CO., LTD ធ្វើប្រតិបត្តិការសិក្សាស្រាវជ្រាវស្វែងរករកធនធានរ៉ែ នៅតំបន់អូរយ៉ាដាវ៖ល៉េ ក្រោម ខេត្តរតនគិរី	២០៨២
១០-១១-១៩៩៥	ប្រកាសលេខ ៨០៣ ផក.ប្រក អនុញ្ញាតអោយលោក ម៉ាន់ នុំ ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	២០៨៤
១០-១១-១៩៩៥	ប្រកាសលេខ៨០៤ ផក.ប្រក អនុញ្ញាតអោយលោក ហ៊ុន ឡុង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកម្លាំង៨០ សេះ	២០៨៥
១០-១១-១៩៩៥	ប្រកាសលេខ ៨០៥ ផក.ប្រក អនុញ្ញាតអោយលោក តាត់ ទុង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកម្លាំង១៦ សេះ	២០៨៦
១០-១១-១៩៩៥	ប្រកាសលេខ ៨០៦ ផក.ប្រក អនុញ្ញាតអោយលោកស្រី អៀវ គឹមយៀង ជនជាតិខ្មែរ បន្តដំណើរការឡផលិតនំប៉័ង ឈ្មោះ « ក្បាលថ្នល់ »	២០៨៦
១០-១១-១៩៩៥	ប្រកាសលេខ ៨០៧ ផក.ប្រក អនុញ្ញាតអោយលោក ទឹម យ៉ុង ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូច ផលិតទឹកបរិសុទ្ធ និងទឹកកកគ្រាប់ សញ្ញា «រូបប្រាសាទបន្ទាយស្រី »	២០៨៧

១០-១១-១៩៩៥	ប្រកាសលេខ ៨០៨ ផក.ប្រក អនុញ្ញាតអោយលោក នួន ផាន្នី ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	២០៨៨
១៣-១១-១៩៩៥	ប្រកាសលេខ ៨១១ ផក.ប្រក អនុញ្ញាតអោយ GAE TENG (CAMBODIA) ENTERPRISE CO.,LTD តំណាងដោយលោកស្រី ជិន យិនជូ ជនជាតិតៃវ៉ាន់ សាងសង់ និងដំណើរការផលិតកម្ម អាជីវកម្ម « រោងចក្រផលិតបន្ទះក្តារ GAE TENG	២០៨៨
១៤-១១-១៩៩៥	ប្រកាសលេខ ៨១២ ផក.ប្រក អនុញ្ញាតអោយលោក គង់ សិកា ជនជាតិខ្មែរ បន្តដំណើរការផលិតកម្ម និងពង្រីកបន្ថែមនូវមុខផលិតផលស្រាកែច្នៃ	២០៩០
១៥-១១-១៩៩៥	ប្រកាសលេខ ៨១៤ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី សៀង ទៀង ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ៨០ សេះ	២០៩០
១៥-១១-១៩៩៥	ប្រកាសលេខ ៨១៥ ផក.ប្រក អនុញ្ញាតអោយលោក ឡុង សម្បត្តិ ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ៨០ សេះ	២០៩១
១៥-១១-១៩៩៥	ប្រកាសលេខ ៨១៦ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី នាង យ៉ា ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកម្លាំង ២៤ សេះ	២០៩២
១៥-១១-១៩៩៥	ប្រកាសលេខ ៨១៧ ផក.ប្រក អនុញ្ញាតអោយលោក ស៊ុយ ស៊ុនហាក់ ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	២០៩២
១៥-១១-១៩៩៥	ប្រកាសលេខ៨១៨ ផក.ប្រក អនុញ្ញាតអោយលោក នៅ សារ៉េត ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	២០៩៣
១៥-១១-១៩៩៥	ប្រកាសលេខ ៨១៩ ផក.ប្រក អនុញ្ញាតអោយ ស្វេះ សុស ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	២០៩៣
១៥-១១-១៩៩៥	ប្រកាសលេខ ៨២០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ដួង	

	តឹមសុង ជនជាតិខ្មែរ បើដំណើរការរោងម៉ាស៊ីនផលិតទឹកកក ដើម	២០៩៤
១៥-១១-១៩៩៥	ប្រកាសលេខ ៨២១ ផក.ប្រក អនុញ្ញាតអោយលោក ម៉ាន ទីន ជនជាតិខ្មែរ បន្តដំណើរការឡផលិតឥដ្ឋក្បឿង	២០៩៥

៤ - ឯកសាររដ្ឋមន្ត្រី ក្រសួងផែនការ

ប្រកាស

០៩-១១-១៩៩៥	ប្រកាសលេខ ១៦ ប្រ.ផក ស្តីពីលទ្ធផលប្រឡងជ្រើសរើសសិស្ស អោយចូលរៀនសាលាមធ្យមសិក្សាផែនការជំនាន់ទី ៨	២០៩៦

៥ - ឯកសារ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

១៣-១១-១៩៩៥	ប្រកាសលេខ ១៦៧ បទ ស្តីពីការផ្ទេរមន្ត្រីរាជការ	២១០៧
១៣-១១-១៩៩៥	ប្រកាសលេខ ១៦៨ បទ ស្តីពីការផ្ទេរមន្ត្រីរាជការ	២១០៨

៦ - ឯកសារ ក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

០២-១១-១៩៩៥	សេចក្តីសំរេច លេខ ២៣៧/៩៥ កធស ស្តីពីការអនុញ្ញាតច្បាប់ អោយបើកសាខាការិយាល័យ នៃក្រុមជំនុំព្រះជាម្ចាស់នៅកម្ពុជា	២១១០
០២-១១-១៩៩៥	សេចក្តីសំរេច លេខ ២៣៨/៩៥ កធស អនុញ្ញាតជាគោលការណ៍អោយបើកព្រះវិហារជីងត៍ន ម៉ុលីក	២១១២
១០-១១-១៩៩៥	សេចក្តីសំរេច លេខ ២៤៨/៩៥ កធស ស្តីពីការទទួលស្គាល់ក្រុមប្រឹក្សាបរិស័ទគ្រិស្ត និកាយប្រូតេស្តង់	២១១៣
១៣-១១-១៩៩៥	សេចក្តីសំរេច លេខ ២៥៣/៩៥ កធស ស្តីពីការអនុញ្ញាតច្បាប់ទទួលស្គាល់គណៈកម្មាធិការ នៃមជ្ឈមណ្ឌលគ្រិស្តសាសនាកម្ពុជា និកាយ ប្រូតេស្តង់	២១១៥

I - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ : ១១៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការនគរបាលជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- អនុក្រឹត្យលេខ ៩៤ អនក្រ. ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ១៩៩៤ ស្តីពីការ តែងតាំងមុខ តំណែងមន្ត្រីរាជការ ផ្នែករដ្ឋបាល និង នគរបាលជាតិ នៃ ក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃលេខ ១៧៤៩ លស. ចុះថ្ងៃ ទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ម៉ូ ឈីដា** ជាប្រធានអង្គភាពប្រឆាំងគ្រឿងញៀន ជំនួសលោក **នួន សឿរ** វិញ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្ដីសម្រេច

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្ដីសម្រេចលេខ ៧៧ សសរ

ស្ដីពីការប្រគល់ភារកិច្ចបណ្ដោះអាសន្ន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- **ផ្អែកតាមការចាំបាច់**

សម្រេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម **ស៊ុំ ម៉ាននិត** រដ្ឋលេខាធិការទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជារដ្ឋលេខាធិការស្ដីទី នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ចាប់ពីថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ រហូតដល់ឯកឧត្តម **ឡោក់ សុខ** ត្រឡប់មកពីបំពេញបេសកកម្មនៅបរទេសវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ស៊ុំ ម៉ាននិត** ត្រូវទទួលអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

សហនាយករដ្ឋមន្ត្រីស្ដីទី
ហត្ថលេខា និង ត្រា
ស ខេង ឃុ ហ៊ុនត្នី

* * *

II - អត្ថបទបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣៦៣ សហវ-ឈស-ប្រក
ស្ដីពីការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការ គ្រប់គ្រងលទ្ធកម្មសាធារណៈ ។
- បានឃើញប្រកាសលេខ ៣១៩ សហវ-ម-ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការ...នុវ...ាន និងបទបញ្ញត្តិ ...ងការគ្រប់គ្រង លទ្ធកម្មសាធារណៈ ។
- បានឃើញការចាំបាច់របស់ ក្រសួង...ដ្ឋកិច្ច និង ហិរញ្ញ...

សំរេច

ប្រការ ១ : ដើម្បីមានសិទ្ធិ ចូលរួមក្នុងការដេញ...លើរាល់គំរោងការងារសាងសង់ សាធារណៈ គ្រប់ប្រភេទ...តាមប... ស្ទួង ស្ថាប័ន និង ខេត្ត ក្រុង ក្រុមហ៊ុន សាងសង់ នៅក្នុងព្រះរា...ចក្រកម្ពុជា ដែលមាន នីតិសម្បទា ត្រឹមត្រូវ ត្រូវតែបានមកចុះឈ្មោះក្នុងបញ្ជី អ្នកទទួលការសាងសង់នៅ នាយកដ្ឋាន លទ្ធកម្មសាធារណៈ នៃ...សួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បី បញ្ជាក់ ពីប្រភេទរបស់ក្រុមហ៊ុន ...ង ចំណាត់ថ្នាក់នៃគំរោងដែលក្រុមហ៊ុន អាចធ្វើបាន ។

ប្រការ ២ : គោលការណ៍ណែនាំ ស្តីពីការបែងចែក...ាមប្រភេទនិងការចុះបញ្ជីអ្នកទទួល ការសាងសង់ ត្រូវ កំណត់ឡើងដោយ...ន...យកដ្ឋានលទ្ធកម្មសាធារណៈ ។

ប្រការ ៣ : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

២ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤៤៧ ពណ.បល.ប្រក

ស្តីពីការប្រគល់ភារកិច្ចបន្ថែមជូនឯកឧត្តម អ៊ុប សី

* * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីកំណត់ស្តីអំពីរបៀបរបបធ្វើការនៃក្រសួងពាណិជ្ជកម្មលេខ ១៨៧៧ ពណ.បល ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- យោងប្រកាសលេខ ០៧២ ពណ.បល.ប្រក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ ក្រសួងពាណិជ្ជកម្ម

សំរេច

ប្រការ ១ : ត្រូវបានប្រគល់ភារកិច្ចបន្ថែមជូន ឯកឧត្តម **តុប សំ** អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្មនូវភារកិច្ច ជាបណ្ដោះអាសន្នបន្ថែមទៀតលើភារកិច្ចដែលមានសព្វថ្ងៃ ដូចមានខាងក្រោមនេះ

១ - ទទួលខុសត្រូវ និងដឹកនាំផ្ទាល់នូវមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ដូចខាងក្រោម ÷

- តាកែវ
- ស្វាយរៀង
- កំពង់ចាម
- ក្រចេះ
- កំពង់ឆ្នាំង
- ពោធិសាត់
- បាត់ដំបង
- កំពង់ធំ
- កោះកុង
- មណ្ឌលគិរី

២ - ចុះហត្ថលេខា សំរេចលើលិខិតបទដ្ឋាននានា អំពីការសុំបង្កើត និងរំសាយ ក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្មឯកជន ។

ប្រការ ២ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស និង ឯកឧត្តម អនុរដ្ឋលេខាធិការ **តុប សំ** ត្រូវទទួលអនុវត្តតាមប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

៣ - ឧស្សិការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៧៩៩ ឧក. ប្រក

* * *

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **សាន ចន្ទ្រៈ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២០២២៤ កព ចុះថ្ងៃទី ១០-៤-១៩៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៩៧ អឺ០ ផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមនរាជធានីភ្នំពេញ បន្តដំណើការសិប្បកម្មកាត់ដេរសំលៀកបំពាក់ និង ស្បែកជើងគ្រប់ប្រភេទ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៨០១ ឧក . ប្រក

អនុញ្ញាតអោយក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT CO.LTD ធ្វើប្រតិបត្តិការសិក្សាស្រាវជ្រាវ ស្វែងរករកធនធានរ៉ែ នៅតំបន់បរខាំ - បរកែវ ខេត្ត រតនគិរី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហា ក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាលកម្ពុជា
- បានឃើញលិខិតអនុញ្ញាតិជាគោលការណ៍ របស់គណកម្មាធិការវិនិយោគ កម្ពុជា លេខ ៨១៩ /៩៥ គវក ចុះថ្ងៃទី ១៤–៩–១៩៩៥
- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុន សិក្សាស្រាវជ្រាវស្វែងរុករកធន ធាន រ៉ែនៅតំបន់បរខាំ–បរកែវ ខេត្តរតនគិរី ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៥
- បានឃើញពាក្យស្នើសុំលិខិតអនុញ្ញាតស្រាវជ្រាវស្វែងរុករកធនធានរ៉ែរបស់ ក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT co.ltd លេខ ១៤/៩៥ ក.ស ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT Co ltd មានអាស័យដ្ឋានផ្ទះលេខ ២៥៨ ផ្លូវ ១៥៦ សង្កាត់ទឹកល្អក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ធ្វើប្រតិបត្តិការសិក្សា ស្រាវជ្រាវស្វែងរុករកធនធានរ៉ែនៅតំបន់ បរខាំ–បរកែវ ខេត្តរតនគិរី លើផ្ទៃ ដី ៧២៥ គីឡូម៉ែត្រក្រឡា មានកូអរដោណេដូចតទៅ ÷

ចំណុច	ខ្សែរយៈទទឹង	ខ្សែរយៈបណ្តោយ
A	107°10"E	13°55'N
B	107°23'50"E	13°55'N
C	107°23'50"E	13°38'32"N
D	107°10'E	13°38'32"N

ប្រការ ២ : ក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT Co ltd ត្រូវដំណើរការ ការងារសិក្សាស្រាវជ្រាវស្វែងរុករកធនធានរ៉ែ លើផ្ទៃដីដែលបានកំណត់នេះដោយធានានូវលក្ខ ការណ៍ បច្ចេកទេស ភូគព្ភសាស្ត្រ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ២ (ពីរ) ឆ្នាំ ។ ផុតកំណត់ពេលនេះ ក្រុមហ៊ុនត្រូវដាក់ពាក្យ សុំការអនុញ្ញាតធ្វើប្រតិបត្តិការសិក្សា ស្រាវជ្រាវស្វែងរុករកធនធានរ៉ែបន្ត ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានល័ក្ខខ័ណ្ឌ ។

ប្រការ ៤ : ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ-រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច ប្រធានមន្ទីរ ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តរតនគិរី និង ប្រធានក្រុមហ៊ុនត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

ភ្នំពេញ , ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨០២ ឧស . ប្រក

អនុញ្ញាតអោយក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT. CO,.LTD ធ្វើប្រតិបត្តិការសិក្សាស្រាវជ្រាវស្វែងរុករកធនធានរ៉ែ នៅតំបន់អូរយ៉ាដាវលើ ក្រោម ខេត្ត រតនគិរី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហា ក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាលកម្ពុជា
- បានឃើញលិខិតអនុញ្ញាតជាគោលការណ៍ របស់គណកម្មាធិការវិនិយោគ កម្ពុជា លេខ ៨១៩ /៩៥ គវិក ចុះថ្ងៃទី ១៤-៩-១៩៩៥
- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុន សិក្សាស្រាវជ្រាវស្វែងរុករក ធនធានរ៉ែ នៅតំបន់ អូរយ៉ាដាវលើ-ក្រោម ខេត្តរតនគិរី ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៥
- បានឃើញពាក្យស្នើសុំលិខិតអនុញ្ញាតសិក្សាស្រាវជ្រាវស្វែងរុករកធនធាន រ៉ែ របស់ក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT Co.ltd លេខ ១៤/៩៥ ក.ស ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT Co ltd មានអាស័យដ្ឋានផ្ទះលេខ ២៥៨ ផ្លូវ ១៥៦ សង្កាត់ទឹកល្អក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ធ្វើប្រតិបត្តិការសិក្សា ស្រាវជ្រាវស្វែងរុករកធនធានរ៉ែនៅតំបន់អូរយ៉ាដាវលើ ក្រោម ខេត្តរតនគិរី លើផ្ទៃដី ៥០៤ គីឡូម៉ែត្រក្រឡា មានកូអរដោណេដូចតទៅ ÷

ចំណុច	ខ្សែរយៈទទឹង	ខ្សែរយៈបណ្តោយ
A	107°22'11"E	13°38'32"N
B	107°33'55"E	13°38'32"N
C	107°33'55"E	13°25'30"N
D	107°22'11"E	13°25'30"N

ប្រការ ២ : ក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT Co ltd ត្រូវដំណើរការ ការងារសិក្សាស្រាវជ្រាវស្វែងរុករកធនធានរ៉ែ លើផ្ទៃដីដែលបានកំណត់នេះដោយធានានូវលក្ខ ការណ៍ បច្ចេកទេសភូគព្ភសាស្ត្រ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ២ (ពីរ) ឆ្នាំ ។ ផុតកំណត់ពេលនេះ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំការអនុញ្ញាត ធ្វើប្រតិបត្តិការសិក្សាស្រាវជ្រាវស្វែងរុករកធនធានរ៉ែបន្ត ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានលក្ខខ័ណ្ឌ ។

ប្រការ ៤ : ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ-រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច ប្រធានមន្ទីរ ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តរតនគីរី និង ប្រធានក្រុមហ៊ុនត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨០៣ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក ខឹវន់ ខុំ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២១៤៧៤១ ត.ក ចុះថ្ងៃទី ១៩-៦-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ គុសថ្មី ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ បើកដំណើរការ

រោង ម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំងភូមិ ត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុក ត្រាំកក់ ខេត្តតាកែវ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨០៤ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ហ៊ីន ឡូត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ៣៨០៣៥៣.ក.ប ចុះថ្ងៃទី ២៩-៤-៨៩ អាស័យដ្ឋានបច្ចុប្បន្នភូមិប្រគាប ឃុំរូងជ្រៃ ស្រុក បាត់ដំបង ខេត្តបាត់ដំបង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ហ៊ីន ឡូត** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុង ប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការ ប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨០៥ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **តាន់ គុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ១១០២៣៤៩ ក.ណ ចុះថ្ងៃទី ០២-៩-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្រោម ឃុំកោះចូរ៉ាម ស្រុក ខ្សាច់កណ្ដាល ខេត្តកណ្ដាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **តាន់ គុង** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្ត ផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការ ប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨០៦ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **អៀវ គីមយៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៤៧៦១៥ ភ.ព ចុះថ្ងៃទី ១៩-៧-៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១១៩អា ផ្លូវជាតិលេខ ២ ភូមិព្រែកតាទូ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បន្តដំណើរការឡផលិតនំប៉័ង យីហោ «ក្បាលថ្នល់» នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំ ការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណ ភាពប៉ះពាល់ដល់ សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨០៧ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយ លោក **ឌឹម យ៉ុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៣៧១៩ កស៤ ចុះថ្ងៃទី ២៧-០១-៨៦ អាស័យដ្ឋាន បច្ចុប្បន្នក្រុម ៤ ភូមិ ព្រែកព្រះស្តេច ឃុំស្វាយប៉ោ ២ ទីរួមខេត្តបាត់ដំបង ខេត្តបាត់ដំបង បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ និងទឹកកក ត្រាប់ សញ្ញា « រូបប្រាសាទបន្ទាយស្រី » នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឌឹម យ៉ុខ** ត្រូវផលិតនូវមុខផលិតផលទឹកបរិសុទ្ធ និងទឹកកក ត្រាប់សញ្ញា «រូបប្រាសាទបន្ទាយស្រី» ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណ ភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨០៨ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយ លោក **ខួន ផាន្នី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៤៣៦១៤ ស្វ.រចុះថ្ងៃទី ២២-១១-៨៥ អាស័យដ្ឋានបច្ចុប្បន្នភូមិរូបគោ ឃុំព្រៃធ្លាក់ ស្រុកស្វាយរៀង ខេត្តស្វាយរៀង បើកដំណើរការរោងម៉ាស៊ីនផលិតទឹកទឹកកកដើមនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណ ភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ភ្នំពេញ , ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៨១១ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយ GAE TENG (CAMBODIA) ENTERPRISE Co.LTD តំណាងដោយលោកស្រី ជិន យិនជូ (**Mrs CHEN YEN CHU**) ជនជាតិ ចិនតៃវ៉ាន់ អាស័យដ្ឋាន ៩៦៦ FENGCHOU RDSHEN KANG HSIANG. TAICHUNG,**TAIWAN** កាន់លិខិតឆ្លងដែនលេខ**M 8166852** ចេញថ្ងៃទី ២៧-៤-៩៣ សាងសង់និងដំណើរការ ផលិតកម្ម-អាជីវកម្ម រោងចក្រកែច្នៃអាចម៍រណា ដែលមានឈ្មោះថា « រោងចក្រផលិតបន្ទះក្តារ **GAE TENG** » ដែលមានទីតាំងនៅភូមិត្រពាំងប្រុយ និង ភូមិត្នោត១ដើម ឃុំ បែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ។

ប្រការ ២ : ការបង្កើតរោងចក្រ ត្រូវធ្វើតាមគំរោង របាយការណ៍ បច្ចេកទេសសេដ្ឋកិច្ច ចុះថ្ងៃទី ២១ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ត្រូវសាងសង់និងរៀបចំរោងចក្ររបស់ខ្លួនអោយបានសំរេចក្នុងរយៈពេល ១២ ខែ រាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បង លើទីតាំងដែលបានកំណត់ក្នុងប្លង់គិតចាប់ពីថ្ងៃដែលបាន ចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ ៣ : សាមីក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ជូន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នូវ ÷

- សកម្មភាពសាងសង់ជារៀងរាល់ខែ ។
- កាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការជាផ្លូវការ ។
- សកម្មភាពផលិតកម្មអាជីវកម្មក្នុងរយៈពេលដំណើរការផលិតកម្មជារៀងរាល់ខែ ។

ប្រការ ៤ : ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវធានាសុវត្ថិភាព ឧស្សាហកម្ម ធានាការពារបរិដ្ឋាន និង ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពច្បាប់ និង បទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៥ : សាមីក្រុមហ៊ុនត្រូវផលិតចេញនូវផលិតផល «បន្ទះក្តារកែច្នៃពីអាចម៍រណា» ទៅតាមគំរូ និងផ្លាកសញ្ញាដែលតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះនឹងដកហូតវិញដោយគ្មានការតវ៉ាឡើយ ។

ប្រការ ៧ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល និង ប្រធានក្រុមហ៊ុន GAE TENG (CAMBODIA) ENTER- PRISE LTD. ត្រូវអនុវត្តតាមប្រកាសនេះតាមមុខការរៀងៗ ខ្លួន ។

ប្រការ ៨ : ប្រកាសនេះមានអានុភាព គតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

* * *

ភ្នំពេញ , ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤១២ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **គង់ សិការ** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ២៤៣៤៣៧ ភ.ព ចុះថ្ងៃទី ២១-៦-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤២២ ផ្លូវជាតិលេខ ៥ ក្រុមទី ៩ ភូមិ ស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម និង ពង្រីកបន្ថែមនូវមុខផលិតផល ស្រាកែច្នៃនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **គង់ សិការ** ត្រូវបានអនុញ្ញាតអោយផលិតនូវស្រាកែច្នៃ សញ្ញា «ផ្លែម្នាស់ » និង «រូបដីរ » បន្ថែមលើមុខផលិតផលចាស់ ចំនួន ២ មុខទៀត គឺ ស្រាកែច្នៃសញ្ញា « ពូថៅមាស « និង « កាំប្រមា » ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបី ឆ្នាំ ។ ផុតពេលកំណត់ពេលនេះម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុង ករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាព ប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៨១៤ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **សៀវ ឡៀវ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៨១៣៥៧ ក.ស្ព ចុះថ្ងៃទី ០៨-៣-១៩៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ មុខខេត្ត សង្កាត់ សន្តិភាព ស្រុក ទីរួមខេត្ត ខេត្តកំពង់ស្ពឺ បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំងភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

ប្រការ ២ : អ្នកស្រី **សៀវ ឡៀវ** ត្រូវបន្តដំណើរផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយ មានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៨១៥ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ឡុង សម្បត្តិ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០១៦៣៤៨ សរ. ចុះថ្ងៃទី ១១-១២-១៩៨៦ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ១ ភូមិ គោកជួន ឃុំពួក ស្រុកពួក ខេត្តសៀមរាប បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំង ក្រុមទី ១ ភូមិ ចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ។

ប្រការ ២ : លោក **ឡុង សម្បត្តិ** ត្រូវចាប់ផ្ដើមដំណើរផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុង ប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៨១៦ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **នាង យ៉ា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៤៥០២៥ ស្វរ ចុះថ្ងៃទី ០៦-១២-១៩៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ឃោសាង ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំង ភូមិថ្មី ឃុំសង្ឃ័រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

ប្រការ ២ : អ្នកស្រី **នាង យ៉ា** ត្រូវចាប់ផ្ដើមដំណើរផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៨១៧ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ស៊ុយ ស៊ុនហាក់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣០០២៨ ស.រ ចុះថ្ងៃទី១៤-៨-៨៨ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ០៤២ ក្រុម៥ ភូមិត ឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប បើកដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំងភូមិអន្លង់សំណរ ឃុំអន្លង់សំណរ ស្រុកជីក្រែង ខេត្តសៀមរាប ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផល គ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រឬ បង្ក អោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៨១៨ ឧក. ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **នៅ សារ៉េន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២៦៥៧៧៧ ក.៣ ចុះថ្ងៃទី ២៥-៨-១៩៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ដូង ឃុំ ព្រែកល្ពៅ ស្រុកពញាឮ ខេត្តកណ្តាល បន្តដំណើរការ រោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។

ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផល គ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៨១៩ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ស្ដេះ សុស** ជនជាតិចាម សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២២៨០៩៦ ក.ណ ចុះថ្ងៃទី ១៣-០១-១៩៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិចាមលើ ឃុំ ព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៨២០ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ជួន គីមស៊ុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៦៣៨៥៨ ក.ព.១ ចុះថ្ងៃទី ២៧-៧-១៩៩០ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ អង្គតាសោម ឃុំ អង្គតាសោម ស្រុក ត្រាំកក់ ខេត្តតាកែវ បើកដំណើរការ រោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ៤២១ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ាន ឌីន**. ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២១៧៧២៣ ភ.ព. ចុះថ្ងៃទី ០៧–៤–១៩៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ តាព្រហ្ម ឃុំ កំពង់អុស ស្រុក ពញាឮ ខេត្តកណ្តាល បន្តដំណើរការ ឡផលិតឥដ្ឋ – ក្បឿង នៅ ក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៤ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងផែនការ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦ ប្រ.ផក
ស្តីពីលទ្ធផលប្រឡងជ្រើសរើសសិស្សអោយ
ចូលរៀនសាលាមធ្យមសិក្សាផែនការជំនាន់ទី VIII

រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងសេចក្តីជូនដំណឹងលេខ ០៣ អយក.សរណន ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់ក្រសួងអប់រំយុវជន និង កីឡា ស្តីពីការរៀបចំ ចាត់តាំង និង ភារកិច្ចរបស់យន្តការគ្រប់គ្រងការប្រឡងជ្រើសរើសសិស្ស អោយចូលរៀននៅក្នុងគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស ។
- យោងតាមសេចក្តីជូនដំណឹងលេខ ៣៣៤ សណ.ផក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ក្រសួងផែនការស្តីពីការប្រឡងជ្រើសរើសសិស្ស ចូលរៀនសាលាមធ្យមសិក្សាផែនការជំនាន់ទី VIII សំរាប់ឆ្នាំសិក្សា ១៩៩៥–៩៦ ។
- យោងប្រកាសលេខ ០៧ ប្រ.ផក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៥ របស់ក្រសួង ផែនការស្តីពីការចាត់តាំងគណៈកម្មការប្រឡងជ្រើសរើស សិស្សចូលរៀនសាលាមធ្យមសិក្សាផែនការ ។
- យោងតាមស្មារតីអង្គប្រជុំអនុម័តលទ្ធផលនៃការប្រឡងជ្រើសរើស ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៥ ។

សម្រេច

ប្រការ ១ : បេក្ខជនទាំងពីរភេទដែលនាមរាយមានក្នុងតារាងឧបសម្ព័ន្ធត្រូវបានទទួលស្គាល់ថា បានប្រឡងជាប់ជាស្ថាពរ ។

ប្រការ ២ : បេក្ខជនទាំងអស់ដូចមាននាយនាមក្នុងតារាងឧបសម្ព័ន្ធត្រូវបានអនុញ្ញាតអោយចូលនៅសាលាមធ្យមសិក្សាផែនការ ។

ប្រការ ៣ : មន្ទីរក្រសួងផែនការ សាលាមធ្យមសិក្សាផែនការ មានភារកិច្ចអនុវត្តសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ជា ចាន់តូ

* * *

ឧបសម្ព័ន្ធទី I

យោងប្រកាសលេខ ១៦ ប្រ ផ.ក

ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

បញ្ជីរាយនាមបេក្ខជនប្រឡងចូល

សាលាមធ្យមសិក្សាផែនការជំនាន់ទី ៨

បន្ទប់	លេខតុ	ឈ្មោះ		ភេទ	ថ្ងៃ—ខែ—ឆ្នាំកំណើត	ផ្សេងៗ
២២	៥២៧	សុខា	ដានីរត្ន័	ស	០៧–១០–៧៨	
២៧	៦៦៦	ហ៊ីង	ចន្ទបុប្ផា	ស	២៨–៦–៧៩	
១៣	៣១៧	ប៉ែន	សុភាព	ស	៣០–១០–៧៨	
៣៣	៨០៨	អ៊ុំ	សុគន្ធា	ស	១៥–៧–៧៨	
១	១២	កែវ	វរលក្ខណ៍	ស	២២–១០–៧៨	
១៤	៣៣០	ពិល	សារឿន	ប	០៥–៤–៧៣	
៨	១៩០	តាំង	វណ្ណរិទ្ធ	ប	២៥–៧–៧៥	

១៦	៣៨៥	ម៉េង	ណារ៉ូ	ប	១៥–៣–៧៦	
៣០	៧៤២	អ៊ុច	សេងអាន	ប	១២–១២–៧៦	
១៥	៣៧០	ម៉ែន	សុភាព	ស	០៣–៧–៧៤	
១៦	៣៩៧	មុំ	សំអឿន	ប	១៤–៥–៦៣	
២២	៥៤១	សាង	ពៅ	ប	០៥–៣–៧៥	
២៥	៦០១	សុទ្ធ	គឹមលាង	ស	០៣–៣–៧៧	
១	២២	កែ	ចន្ទ្រា	ប	០៧–៤–៧៤	
៤	៨៧	ឆាង	លាងរិទ្ធិ	ប	១២–០១–៧៤	
៥	១១៥	ជិន	បូរង្ស	ប	១៥–១០–៧៦	
៦	១៤៧	ឈើន	សុជា	ស	០៥–៧–៧៨	
១៩	៤៦៧	រ៉ាន់	ណារី	ស	០៣–១០–៧៨	
២៧	៦៥៥	ហ៊ុន	សាមិត្ត	ប	១២–៨–៧៨	

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

គណៈកម្មការប្រឡងជ្រើសរើស

ប្រធាន

ហត្ថលេខា និង ត្រា

[illegible]

* * *

ឧបសម្ព័ន្ធទី II

សេចក្តីប្រកាសលេខ ១៦ ក្រប [illegible]

ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

[illegible]

[illegible]

បន្ទប់	លេខតុ	ឈ្មោះ	ភេទ	ថ្ងៃ—ខែ—ឆ្នាំកំណើត	ផ្សេងៗ
២៩	៧០៩	អាន ដារា	ប	២៧-៩-៧៥	
២៩	៧២៣	អ៊ុយ ចំរើនរតនា	ប	១៣-០២-៧៥	
៣៣	៨១៥	អ៊ា ឈាង	ប	១១-៣-៧៣	
៧	១៧០	ផែក ប៊ុនធឿន	ប	០៥-០១-៧៥	
១១	២៥៤	នៅ សុខជាប	ប	៣០-១០-៧៦	
១១	២៦៨	នៅ វិន	ប	២០-១១-៧៦	
១១	២៧៤	នេត្រ ភារម្យ	ប	១៥-១២-៧៨	
១៣	៣០៤	ប៉ាល់ សុធារី	ស	២៣-៩-៧៧	
១៥	៣៥១	ភេម ស៊ីផន	ប	១០-១១-៧៨	
១៨	៤៤៧	លីវ សុខភាព	ប	២០-៨-៧៧	
២៩	៧១៦	អាក់ សំអាង	ស	១៧-៥-៧៧	
២៩	៧២១	អ៊ុំ សុគន្ធធីតា	ស	០១-៥-៧៦	
៦	១៤៥	ឈឹម ចន្ថា	ស	១៥-០២-៧៨	
១៧	៤១០	យី សុភា	ស	២៥-១២-៧៧	
១៨	៤៤៥	លាង សឹង	ប	២៧-៥-៧៤	
១៩	៤៥៧	លឹម ទ៊ី	ប	១៨-៩-៧៧	
១៩	៤៦១	លឹម កេតកញ្ញា	ស	២៧-៩-៧៥	
២០	៤៨៦	វង់ ស្សិរិយាភាព	ប	១៦-៦-៧៤	
២១	៥១៥	សុខ សារឿន	ប	០៣-៥-៧៩	

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

គណៈកម្មការប្រឡងជ្រើសរើស

ប្រធាន

ហត្ថលេខា និង ត្រា

សាន វិចណ្ណៈ

ឧបសម្ព័ន្ធទី III

យោងប្រកាសលេខ ១៦ ប្រ ដ.ក

ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

បញ្ជីរាយនាមលទ្ធផលប្រឡងចូល

សាលាមធ្យមសិក្សាផែនការជំនាន់ទី ៨

បន្ទប់	លេខតុ	ឈ្មោះ	ភេទ	ថ្ងៃ—ខែ—ឆ្នាំកំណើត	ផ្សេងៗ
២៧	៦៥៨	ហ៊ុន ភិរុណ	ប	០៤–១០–៧៥	
២៩	៧០២	ឡុង សុភាព	ប	១៣–៨–៧៦	
៦	១៤១	ឈិត សុផាន	ស	១២–៤–៧៧	
៨	១៧៨	ណី តេងស៊ីវុត្ថាវិក្រា	ប	០៩–០១–៧៥	
៩	២០៦	ថាវ ថារត្ន័	ស	០៥–៦–៧៧	
១២	៣០០	ប៉េង ម៉េង	ប	០១–៦–៧៨	
១៥	៣៥៩	ម៉ម ម៉ុល	ប	០២–០២–៧៦	
១៧	៤១៥	យិន ណាត	ប	០១–០១–៧៩	
២២	៥៣៦	ស្លួស សុខលី	ស	០១–៧–៧៧	
២៤	៦០០	ស៊ឹម សាបូទ្ធិ	ប	១១–១១–៧៥	
២៥	៦០៧	សុង សុគណ្ឋី	ប	០៨–០១–៧៦	
២៨	៦៩២	ឡុង ឃុន	ប	០៨–៧–៧៨	
២៩	៧០៨	អ៊ុំ ចាន់ណា	ប	១៥–១១–៧៧	
២៩	៧១៩	អ៊ុំ ស្រស់ពិសី	ប	១១–០១–៧៧	
៣១	៧៦៧	អ៊ឹម វាសនា	ប	០២–០២–៧៦	
៣	៥៣	ឃ្លាំង សុខា	ប	០១–០២–៧៤	
៥	១១០	ជាលី បូទ្ធី	ប	២២–០១–៧០	

១១	២៧១	នៅ	សុថានិត	ប	០៥–១០–៧៥	
១៣	៣១១	ប្រាជ្ញ	ច័ន្ទម៉ាលី	ស	០១–០១–៦៥	

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

គណៈកម្មការប្រឡងជ្រើសរើស

ប្រធាន

ហត្ថលេខា និង ត្រា

សាង វិចណ្ណៈ

* * *

ឧបសម្ព័ន្ធទី IV

នៃប្រកាសលេខ ១៦ ប្រ.ក

ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

បញ្ជីរាយនាមបេក្ខជនជាប់ប្រឡងចូល

[illegible] ទី ៤

បន្ទប់	លេខតុ	ឈ្មោះ		ភេទ	ថ្ងៃ–ខែ–ឆ្នាំកំណើត	ផ្សេងៗ
១៣	៣១[illegible]	ប៊ិច	គឹមសុង	ប	១៥–០២–៧៧	
២២	៥៤៣	សម្ប	កុសល	ស	០៩–៨–៧៦	
២២	៥៣៥	សុខ	ភីរ៉	ប	០៥–៥–៧៦	
២៥	៦២២	ស្រី	ចាន់ធឿន	ប	០៦–៦–៧៤	
៣៣	៨០៧	ឈឿន	ណារ៉ាដេត	ស	០២–៣–៧៨	
៣	៦០	ឃ្លាំង	សាខន	ប	០៧–០១–៧៦	
៤	៩៣	ឆាយ	រ៉េមី	ស	១៧–១២–៧២	
៥	១១១	ជា	គិន	ស	១១–០១–៧៨	
៥	១២៤	ជា	ចន្ធូ	ស	១៦–៨–៧៧	

១៣	៣១២	ប៉ោក ចាន់ណារី	ប	០២-៨-៧៨	
១៦	៣៨៩	មួន រេមី	ប	១៤-៧-៧៤	
២០	៤៩២	សួន សុភក្រ័	ស	២៥-៦-៧៧	
២១	៥១០	សុខ វាសនា	ប	៣០-៣-៨០	
២៤	៥៨៧	សួនសៅ សុវតី	ស	០៤-០២-៧៩	
៣២	៧៧៦	ហេង ដារ៉ា	ប	១០-០១-៧៥	
៣២	៧៧៨	ម៉ៅ ធីម	ប	១៥-០២-៧៣	
៣២	៧៨០	ស៊ឹម ណារី	ស	០១-៣-៧០	
១១	២៦២	ទួន ឡារី	ស	២៣-១២-៧៨	
១៥	៣៦២	ម៉េង លីណា	ស	១៧-១១-៧៥	

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

គណៈកម្មការប្រឡងជ្រើសរើស

ប្រធាន

ហត្ថលេខា និង ត្រា

សាន វីវណ្ណៈ

* * *

ឧបសម្ព័ន្ធទី V

យោងប្រកាសលេខ ១៦ ប្រក ឆ.ក

ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

បញ្ជីរាយនាមបេក្ខជនប្រឡងចូល

សាលាមធ្យមសិក្សាផែនការជំនាន់ទី ៨

បន្ទប់	លេខតុ	ឈ្មោះ	ភេទ	ថ្ងៃ-ខែ-ឆ្នាំកំណើត	ផ្សេងៗ
១៦	៣៩៤	មាន សុផល	ប	០២-៣-៧៥	

១៧	៤០៨	យិន	ហាន	ប	១១-១១-៧២	
២២	៥៣១	សំ	រ៉ែម	ប	១១-១២-៧៦	
២៣	៥៥៧	សោម	ប៊ុនណាត	ប	២៨-១២-៧៤	
២៥	៦១៦	សួស	សារិន	ប	១៥-១០-៧២	
២៨	៦៧៩	ហោ	ផល្លា	ស	០១-៦-៧៧	
៣១	៧៥៥	អឿ	សារ៉ាវី	ស	២៨-៣-៧៥	
៣១	៧៦៦	អ៊ុង	ពិសិដ្ឋ	ប	០៥-១០-៧៧	
៣១	៧៧៥	អ៊ឹម	សុវណ្ណារី	ស	០១-០១-៧៨	
៣៣	៨១០	រត្ន័	ប៊ុនធឿន	ប	១៧-៤-៧០	
៣៣	៨១៦	ថៅ	សុខចំរើន	ប	១០-១០-៧៦	
៤	៧៩	ចាប	សុជាតា	ស	២០-៤-៧២	
៥	១០៩	ជីវ	រ៉ា	ប	២០-១១-៧៥	
៧	១៥៣	ឈរ	សុខុម	ស	០៧-០១-៧៩	
១២	២៧៧	ទី	សំអាត	ប	០១-០១-៧៤	
១៥	៣៦៦	ម៉ៅ	សុខជា	ប	២០-៤-៧៦	
១៦	៣៩០	មួន	វឌ្ឍនា	ប	០៤-៧-៧៨	
២០	៤៨៧	រ៉ា	ឆន	ប	០៣-៤-៧៨	
២០	៤៩៨	សាន់	ឈាង	ប	០៥-៧-៧៨	

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

គណៈកម្មការប្រឡងជ្រើសរើស

ប្រធាន

ហត្ថលេខា និង ត្រា

សាន់ វិចេណ្ណៈ

* * *

ឧបសម្ព័ន្ធទី VI

យោងប្រកាសលេខ ១៦ ប្រ ផ.ក

ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

បញ្ជីរាយនាមលទ្ធផលប្រឡងចូល

សាលាមធ្យមសិក្សាផែនការជំនាន់ទី ៨

បន្ទប់	លេខតុ	ឈ្មោះ		ភេទ	ថ្ងៃ—ខែ—ឆ្នាំកំណើត	ផ្សេងៗ
២១	៥០១	សៀ	វិទ្ធី	ប	១១–៧–៧៨	
២២	៥៤៨	សេក	សុវាសនា	ប	០៣–៣–៧៥	
២៤	៥៧៩	ស៊ាង	សីម៉ា	ស	២១–១១–៧៦	
២៦	៦៣២	ហ៊ួ	វ៉ាន់ថន	ប	២៣–៧–៧៥	
២៨	៦៧៨	ហ៊ីង	កុលសំណាង	ប	១៥–៤–៧៦	
២៨	៦៨៦	ឡេង	ប៊ុនធឿន	ប	១២–៤–៧៧	
២៨	៦៩១	ឡុង	ស៊ីម	ប	១៤–៩–៧៦	
២៨	៦៩៨	ឡេា	សុខអ៊ីម	ស	១៧–០២–៧៨	
៣២	៧៨៧	រស់	វីរិយធន	ប	១៥–០១–៧២	
៣២	៧៨៨	នូ	ភីរុណ	ប	០១–០១–៧៣	
៣២	៧៩២	ជាម	ផន	ប	០២–៦–៧០	
៣២	៧៩៦	យែម	សុខលី	ប	០៨–៩–៧០	
៣២	៧៩៧	សិរិត	ទ្វី	ប	០១–៦–៦៨	
៣៣	៨០១	អ៊ឹង	វណ្ណតន្ទី	ស	០៥–៣–៧៣	
៣៣	៨១៣	រាជ	រតនី	ស	០៣–៥–៧១	
៣៣	៨១៤	អ៊ុក	ស៊ីណាន់	ស	១០–៧–៧០	
២	២៦	ខាន់	សុផានី	ប	០៣–៣–៧៥	

៤	៩៤	នឹង វាសនា	ប	១១-០១-៧៥	
៤	៩៥	ឆាយ ភក្តី	ប	០៤-១២-៧៥	

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
គណៈកម្មការប្រឡងជ្រើសរើស
ប្រធាន
ហត្ថលេខា និង ត្រា
សាន វិចណ្ណៈ

* * *

ឧបសម្ព័ន្ធទី VII
យោងប្រកាសលេខ ១៦ ប្រ ជ.ក
ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
បញ្ជីរាយនាមលទ្ធផលប្រឡងចូល
សាលាមធ្យមសិក្សាផែនការជំនាន់ទី ៤

បន្ទប់	លេខតុ	ឈ្មោះ	ភេទ	ថ្ងៃ-ខែ-ឆ្នាំកំណើត	ផ្សេងៗ
៧	១៥១	ឈរ សុខា	ប	១៦-០២-៧៧	
៩	២២៣	ទឹម សណ្ដាន	ប	០៦-៩-៧៥	
១០	២៤០	ជឿន សុទ្ធន	ស	០៥-១២-៧៦	
១៣	៣១០	ប្រាក់ វិសាល	ប	០៥-៤-៧៦	
១៩	៤៥៤	លី ម៉េងហៀន	ប	០៦-៤-៧៥	
១៩	៤៦៥	លឹម ផេង	ប	១០-១២-៧៦	
២០	៤៩៣	សន់ គុណាឌី	ប	០៦-៥-៧៥	
២១	៥០៦	សីថ្លា ស៊ាងឡេង	ប	១៦-០២-៧៥	
២២	៥៤៥	សៀង នាគ	ប	០២-៩-៧៨	

២២	៥៤៧	សុខ សុធិ	ប	០៦-៦-៧៦	
២៣	៥៦៨	សេង រតនា	ប	១៨-៦-៧៦	
២៦	៦៣១	ហែល ហេង	ប	០៧-៨-៧៣	
២៨	៦៨៣	ហង្ស ជ័យសិទ្ធិ	ប	២៦-១១-៧៥	
៣០	៧២៩	អ៊ុំ យុទ្ធី	ប	១៩-៣-៧៨	
៣១	៧៥១	អ៊ុន ស្រីរត្ន័	ស	០៧-៤-៧៧	
៣១	៧៥៩	អ៊ុន រដ្ឋា	ប	០៦-៧-៧៨	
៣២	៧៧៧	ស៊ុក សឿន	ប	០៩-១០-៧៣	
៣២	៧៧៩	អ៊ឹង វណ្ណលី	ស	១៩-៧-៧៣	
៣២	៧៨១	សៅ សុង	ប	១៨-៨-៦៩	

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

គណៈកម្មការប្រឡងជ្រើសរើស

ប្រធាន

ហត្ថលេខា និង ត្រា

សោម រិទ្ធិវណ្ណៈ

* * *

ឧបសម្ព័ន្ធទី VIII

សេចក្តីប្រកាសលេខ ០៦ ប្រ ជ.គ

ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

បញ្ជីរាយនាមបេក្ខជនដែលប្រឡងជាប់ស្ថាពរ

ដោយការប្រឡងជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការ ទី ៥

លំដាប់	លេខតុ	ឈ្មោះ	ភេទ	ថ្ងៃ-ខែ-ឆ្នាំកំណើត	ផ្សេងៗ
៣២	៧៨២	វៀប សុជាតិ	ប	១០-៩-៧៣	

៣២	៧៨៩	នេត	វិសាល	ប	០២-៤-៧៥	
៣២	៧៩០	ឌឹម	ឌន	ប	១៧-៨-៧១	
៣២	៧៩១	ឈឹម	សុផុន	ប	១៧-៣-៧៤	
៣២	៧៩៥	ស៊ឹម	ធឿន	ប	០៥-៣-៦៩	
៣២	៧៩៨	មួង	ណារិទ្ធ	ប	០១-០១-៧៣	
៣៣	៨០២	ចាន់	ងួនប៉ូលីណា	ស	១៥-៦-៧២	
៣៣	៨០៣	ញ៉ាញ់	ជីញ៉ក់	ប	១៦-៧-៧៣	
៣៣	៨០៤	ចាន់	ណារុន	ប	១០-០១-៧៥	
៣៣	៨០៦	ចាន់	ជាលីដា	ស	០៧-៤-៧៣	
៣៣	៨០៩	លឹម	ណារី	ស	០១-៧-៧២	
៣៣	៨[illegible]១	ទុយ	ស៊ុនណារី	ស	០១-៩-៦២	
៣៣	៨១៧	ជាម	គឹមអ៊ីម	ប	១៥-០២-៧៥	

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

គណៈកម្មការប្រឡងជ្រើសរើស

ប្រធាន

ហត្ថលេខា និង ត្រា

សាន វិចណ្ណៈ

* * *

៥ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៧ បន

ស្តីពីការផ្ទេរមន្ត្រីរាជការ

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍
និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ១៩៩៤
- បានឃើញកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះរវាងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ក្រុមហ៊ុនអាំងូសាត ស្តីពីការស្តារ និងពង្រីកអតីតបណ្តាញទូរគមនាគមន៍ អ៊ិនតាក់ នៅ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសលេខ ១៥៥ ប.ទ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : លោក **ជ័យ សុខវណ្ណឌី** បរិក្ខាហេតុៈរងក្បាប់រួមមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តស្ទឹងត្រែង អោយទៅបំរើការងារនៅក្រុមហ៊ុនខាំមីនតែល បន្ថែមលើមុខងារសព្វ ថ្ងៃ ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ តទៅ ។

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួនក្រសួង និងរក្សាទុកដដែលគ្រាន់តែទទួលប្រាក់ភារកិច្ចបន្ថែមលើការងារសព្វថ្ងៃ ។ រីឯការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមពីក្រុមហ៊ុន គឺអាស្រ័យនៅលើក្រុមហ៊ុនខាំមីនតែលជាអ្នកផ្តល់ទៅតាមសមត្ថភាពជំនាញបច្ចេកទេស និងលទ្ធភាពនៃការងារ ។

ប្រការ ៣ : ខុទ្ទកាល័យ , អធិការដ្ឋាន , នាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញកិច្ច , នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស, មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តស្ទឹងត្រែង និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារ នៃប្រកាស នេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃដូចមានចែងក្នុងប្រការ ១ ខាងលើ ។

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៨ ប ខ

ស្តីពីការផ្ទេរមន្ត្រីរាជការ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍

និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ,
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ១៩៩៤
- បានឃើញកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះរវាងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ក្រុមហ៊ុនអាំងដូសាត ស្តីពីការស្តារ និង ពង្រីកអតីតបណ្តាញទូរគមនាគមន៍ អ៊ុនតាក់ នៅ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតបង្គាប់ការលេខ ១៣២ ប.ខ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ : លោក **ឃុំ គីលីន** បជិត្តាហកៈរងគ្គប់រួមមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្តបន្ទាយមានជ័យ អោយទៅបំរើការងារនៅក្រុមហ៊ុន

ខាំមីនតែល បន្ថែមលើមុខងារសព្វថ្ងៃចាប់ពី ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ តទៅ ។

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួនក្រសួង និងរក្សាទុកដដែលគ្រាន់តែ ទទួលប្រាក់ការកិច្ចបន្ថែមលើការងារសព្វថ្ងៃ ។ រីឯការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមពីក្រុមហ៊ុន គឺអាស្រ័យនៅលើក្រុមហ៊ុនខាំមីនតែល ជាអ្នកផ្តល់ទៅតាមសមត្ថភាពជំនាញបច្ចេកទេស និងលទ្ធផលនៃការងារ ។

ប្រការ ៣ : ខុទ្ទកាល័យ , អធិការដ្ឋាន , នាយកដ្ឋានផែនការគណនេយ្យ -ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស, មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារ នៃប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃដូចមានចែងក្នុងប្រការ ១ ខាងលើ ។

ហត្ថលេខា និង ត្រា

សូ ឃុន

*

៦ - ទីស្តីការ ក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ២៣៧/៩៥ ក.ធ.ស

ស្តីពីការអនុញ្ញាតច្បាប់អោយបើកសាខាការិយាល័យមួយនៃក្រុមជំនុំព្រះជាម្ចាស់នៅកម្ពុជា

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងទី ២របស់ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះចៅ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញសំណើសុំបង្កើតសាខាស្នាក់ការមួយកន្លែង នៃក្រុមជំនុំក្រុមជំនុំព្រះជាម្ចាស់នៅកម្ពុជា ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៥ ។

សម្រេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើកសាខាស្នាក់ការមួយកន្លែង នៃ ក្រុមជំនុំព្រះជាម្ចាស់ នៅកម្ពុជា ដែលមានអាស័យដ្ឋាននៅផ្ទះលេខ ៥៨ អឺអា ៥៨អឺបេ ៥៨អឺសេ ៥៨ អឺដេ ផ្លូវ លេខ ១១០ ក្រុមទី ៦ សង្កាត់ ផ្សារដេប៉ូ ៣ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ក្រុមជំនុំព្រះជាម្ចាស់នៅកម្ពុជា ត្រូវអនុញ្ញាតអោយបង្រៀនព្រះគម្ពីរ និង ផ្សព្វផ្សាយនូវលទ្ធិសាសនាគ្រិស្ដដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : «ក្រុមជំនុំព្រះជាម្ចាស់នៅកម្ពុជា »ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណា ចក្រកម្ពុជា និង បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្ដាប់ធ្នាប់សង្គម ។

ប្រការ ៤ : «ក្រុមជំនុំព្រះជាម្ចាស់នៅកម្ពុជា » ត្រូវអនុវត្តន៏តាមសេចក្ដីសំរេចនេះរាល់ការអនុវត្តន៏ ផ្ទុយពីសេចក្ដីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធ ត្រូវសហការ អនុវត្តន៍សេចក្តីសំរេចខាងលើនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហៀង ចន្ទរ័ត្ន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២៣៨/៩៥ ក.ធ.ស

អនុញ្ញាតជាគោលការណ៍ឱ្យបើកព្រះវិហារ

ខ្ញុំតន់មុំលឹក

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងទី២ របស់ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការរបស់ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញសំណើសុំច្បាប់អនុញ្ញាតរបស់សមាគម មុំលឹក នា ខែសីហា ឆ្នាំ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកព្រះវិហារ **ជីងគន់ ម៉ីលីក** មួយកន្លែង ដែលមានទី តាំងស្ថិតនៅ ក្រុមទី ៣ ភូមិក្នុងព្រែក ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ។

ប្រការ ២ : ព្រះវិហារជីងគន់ ម៉ីលីក ត្រូវបានអនុញ្ញាតអោយផ្សព្វផ្សាយ នូវសាសនាម៉ីលីកដែលមាន លក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ព្រះវិហារជីងគន់ ម៉ីលីក ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃ ព្រះរាជាណាចក្រ កម្ពុជា និង បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និង សាសនា សន្យាជាដាច់ខាតមិនធ្វើ អោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាង ជំនឿសាសនា និង សណ្ដាប់ធ្នាប់សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្ដីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្ដីសំរេចនេះមានអានុភាពតតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហៀង ចន្ទរ័ត្ន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្ដីសំរេចលេខ ២៤៨/៩៥ ក.ធ.ស

ស្ដីពីការទទួលស្គាល់ក្រុមគ្រីស្ទ

បរិសុទ្ធគ្រីស្ទ និកាយប្រូតេស្តង់

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងទី ២ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីណែនាំលេខ ៨៦២ កធស.នស ចុះថ្ងៃទី១២ ខែ តុលា ឆ្នាំ១៩៩៤ របស់ក្រសួងធម្មការ និង សាសនា ស្តី អំពីការគោរពប្រតិបត្តិសាសនាគ្រិស្ត នៅព្រះ រាជាណាចក្រកម្ពុជា ។
- បានឃើញបទបញ្ជារបស់ក្រសួងធម្មការ និងសាសនា ចំពោះសាសនាផ្សេងៗ លេខ ៦៤៣.៩៥ កធស ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៥ ។
- យោងសេចក្តីសំរេចអង្គប្រជុំលើកទី១ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការ ជ្រើសរើសក្រុមប្រឹក្សាបរិស័ទគ្រិស្ត ។
- យោងសេចក្តីសំរេចអង្គប្រជុំលើកទី២ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ ជ្រើសរើសក្រុមប្រឹក្សាបរិស័ទគ្រិស្ត ។

សំរេច

ប្រការ ១ : ទទួលស្គាល់ក្រុមប្រឹក្សាបរិស័ទគ្រិស្ត (និកាយប្រូតេស្តង់) ជាតំណាងអោយបរិស័ទគ្រិស្ត (និកាយប្រូតេស្តង់) នៅព្រះរាជាណាចក្រកម្ពុជា ដែលមានឈ្មោះដូចខាងក្រោម ÷

- គណៈកម្មាធិការសម្ព័ន្ធគ្រិស្ទាន ដំណឹងល្អខ្មែរ
- គណៈកម្មាធិការសហព័ន្ធគ្រិស្ទានបរិស័ទខ្មែរ
- ប្រិយសម្ព័ន្ធគ្រិស្ទានខ្មែរ ។

ប្រការ ២ : ក្រុមប្រឹក្សាបរិស័ទគ្រិស្ត (និកាយប្រូតេស្តង់) ត្រូវអនុញ្ញាតអោយបំពេញនូវតួនាទីជាជំនួយការដល់ព្រះវិហារ និងដល់បរិស័ទគ្រិស្តនូវរាល់ការងារផ្សេងៗ ដែលពាក់ព័ន្ធជា មួយការងារសាសនាគ្រិស្ត (និកាយប្រូតេស្តង់) ។

ប្រការ ៣ : ក្រុមប្រឹក្សាបរិស័ទគ្រិស្ត (និកាយប្រូតេស្តង់) ត្រូវគោរពតាមលក្ខន្តិកៈ នៃក្រុមនីមួយៗ ដែលមានតំកល់នៅក្រសួង ករណីមានការកែប្រែលក្ខន្តិកៈ ឬការផ្លាស់ប្តូរសមាសភាព ដឹកនាំត្រូវជូនដំណឹង និងសុំការឯកភាពពីក្រសួង ។

ប្រការ ៤ : ក្រុមប្រឹក្សាបរិស័ទគ្រិស្ត (និកាយប្រូតេស្តង់) ត្រូវមានសាមគ្គីល្អ និងត្រូវគោរពអោយ បានម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេង ។ របស់ក្រសួង ធម្មការ និងសាសនា សន្យាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿ សាសនា និង សណ្តាប់ធ្នាប់សង្គម ។

ប្រការ ៥ : ក្រុមប្រឹក្សាបរិស័ទគ្រិស្ត (និកាយប្រូតេស្តង់) ត្រូវអនុវត្តន៍តាមសេចក្តីសំរេចនេះ រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៦ : នាយកដ្ឋានសាសនា និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការ អនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ។

ប្រការ ៧ : សេចក្តីសំរេចនេះមានអានុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ហត្ថលេខា និង ត្រា

ហៀង ចន្ទណារិទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២៥៣/៩៥ កធស

ស្តីពីការអនុញ្ញាតច្បាប់ទទួលស្គាល់គណៈកម្មាធិការ នៃ មជ្ឈមណ្ឌលគ្រិស្តសាសនា កម្ពុជានិកាយប្រូតេស្តង់

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពី ការតែងតាំងរដ្ឋមន្ត្រីទី១ និងទី២ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃរាជរដ្ឋាភិបាល របស់ព្រះរាជាណាចក្រកម្ពុជា ។
- យោងអង្គប្រជុំពិភាក្សាតំណាងគ្រិស្ដបរិស័ទ ដែលប្រព្រឹត្តទៅនៅក្រសួងធម្មការ និង សាសនា នាថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៥ ។
- បានឃើញលិខិតស្នើរទទួលស្គាល់របស់ « មជ្ឈមណ្ឌលគ្រិស្ដសាសនាកម្ពុជា និកាយ ប្រូតេស្តង់ » ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : ទទួលស្គាល់គណៈកម្មាធិការ នៃមជ្ឈមណ្ឌលគ្រិស្ដសាសនាកម្ពុជា និកាយប្រូតេស្តង់ជាផ្លូវ ការនៅព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : គណៈកម្មាធិការ នៃមជ្ឈមណ្ឌលគ្រិស្ដសាសនាកម្ពុជា និកាយប្រូតេស្តង់ » ត្រូវគោរពតាម លក្ខន្តិកៈ របស់មជ្ឈមណ្ឌលគ្រិស្ដសាសនាកម្ពុជា និកាយប្រូតេស្តង់ ដែលមានតំកល់ទុក នៅក្រសួង រាល់ការកែប្រែលក្ខន្តិកៈថ្មីត្រូវមានឯកភាពពីក្រសួង ។

ប្រការ ៣ : «គណៈកម្មាធិការ នៃមជ្ឈមណ្ឌលគ្រិស្ដសាសនាកម្ពុជា និកាយប្រូតេស្តង់ » ត្រូវសហការ អោយបានល្អជាមួយអង្គភាពពាក់ព័ន្ធ ករណីមានការផ្លាស់ប្ដូរសមាសភាពដឹកនាំត្រូវមាន ការជូនដំណឹងមកក្រសួង ។

ប្រការ ៤ : «គណៈកម្មាធិការ នៃមជ្ឈមណ្ឌលគ្រិស្តសាសនាកម្ពុជា និកាយប្រូតេស្តង់» ត្រូវគោរព អោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនារក្សាអោយបាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គម ។

ប្រការ ៥ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៦ : នាយកដ្ឋានសាសនា និងមន្រ្តីរាជការគ្រប់លំដាប់ថ្នាក់ដែលមានការពាក់ព័ន្ធ ត្រូវសហ ការអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៧ : សេចក្តីសំរេចនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហៀង ចន្ទរ័ត្ន

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៧២៨ រៀល